សុទ្ធតែសម្តពព្រះរាជធិតាមិនមានព្រះរាជឱរស ។

សម្តេចចៅហ្វាទលហៈមានបុត្រប្រុស៣នាក់ មានគម្រេះបេះដឹង បានធ្វើជាចាងហ្វាងមហាតលិកម្នាក់ដែលជាបងបង្អស់ ។ ប្អូន២នាក់ទៀតធ្វើការក្នុងព្រះឃ្លាំងមហាសម្បត្តិ បានបន្លំយកគ្រឿងមាស និងប្រាក់ច្រើន ។ កាលសម្តេចចៅហ្វាជាបិតា នៅជាចាងហ្វាងព្រះឃ្លាំងក៏បានបន្លំយកព្រះរាជទ្រព្យបានច្រើន ។ ឯព្រះរាជទ្រព្យសុទ្ធតែមានសំគាល់ដោយត្រាចំឡាក់ជារូបព្រះមកុដព្រះខាន់ ។ តែពួកអ្នកលួចបន្លំនេះយកទៅកែលុបរូបដើមចេញ ហើយឲ្យឆ្លាក់ជាក្បាលកហូព្រះនារាយណ៍ បែងកាន់គង់លើតាមរូបត្រាទីសម្តេចចៅហ្វា ។

សម្តេចចៅហ្វាបានយកក្មួយស្រីបង្កើតម្នាក់មកចិញ្ចឹមធ្វើកូន ឈ្មោះនាងចន្ទសុតា រូបឆោមល្អស្អាត គំនិតមារយាទក៏សុភាពរៀបរយចេះអក្សរលេខដូចបុរស ។ តាំង



ពីនាងសារកី បានទៅធ្វើជាស្នំឯក នោះនាងចន្ទសុតានៅមិនទាន់គ្រប់ការ ទើបបានអាយុជាង ១៣ ឆ្នាំ ។ សម្តេចចៅហ្វាយទឹកស្តាយណាស់ ព្រោះចាប់ពិសមិនទាន់នាងសារកី ប៉ុន្តែនៅក្នុងគំនិតចាំតែរកឧបាយនឹងកំចាត់នាងសារកីចេញឲ្យបាន ដើម្បីយកក្មួយរបស់ខ្លួនទៅថ្វាយជាព្រះស្នំវិញ ។ លុះដឹងថានាងសារកីប្រសូត្រព្រះរាជឱរសស្រស់ល្អ ហ្លួងសព្វព្រះរាជហឫទ័យណាស់ សម្តេចចៅហ្វាយក៏រឹតតែមិនសប្បាយចិត្តសោះ ។

ព្រះករុណាទ្រង់លើកនាងសារកីព្រះស្នំឯកជាចៅចមហាកា តាំងព្រះនាមជាចៅចមផលចិត្តសុវណ្ណ ឲ្យធ្វើយឬខ្លួលតាមរបៀបក្សត្រ ។ ចៅចមមាតាប្រសូត្រព្រះរាជឱរសបាន ១០ ខែហើយទើបហ្លួងសក្តាលើកទ័ពមកដល់ក្រុងលង្វែកវិញ ។

ហ្លួងសក្តាដឹងថាប្អូនធម៌ឡើងយសដូចចមហេសី មាន

ទាំងព្រះពជបុត្រជាបកុជកុមារ ក៏អរស្ងើរសរសើរគុណខ្លួន ។ កុងឈិនបានទៅរកសិនសែនទៅកំពុងល្អង ឲ្យតាយកាម ផ្ទាំងខព្រះពជទុរស ។ សិនសែថាមិនឃើញខ្លួនទីងតាយមិន អស់ តែបើតាមយាមថា កូនស្តេចនោះនឹងជំណាងជ ពុំបាន ប៉ុន្តែតុងខាងដើម ដល់ខាងក្រោយទើបល្អ ។

## វគ្គទី១០

ហ៊ុនសក្កាអស់កិច្ចការ ក៏ចូលទៅលាលោកមេទ័ព ត្រឡប់ទៅសួរមាតាទីងករិយា ឯគូម៉ិប្រាសាទ ខេត្តបន្ទាយមាស ។

មេទ័ពអនុញ្ញាតឲ្យច្បាប់ ៣ អាទិត្យ ឲ្យត្រឡប់មកដល់វិញ ។ កាលបើទៅដល់ផ្ទះហើយហ៊ុនសក្កាក៏ចូលទៅក្រាបសំពះមាតា ព្រមទាំងសួរសុខទុក្ខសព្វសារពើ ។ មាតាក៏សាស័ព្ទប្រាប់ដំណើងអំពីរឿងប្រពន្ធដែលប្រព្រឹត្តមិនសមគួរ បានខូចខាតប្រវៅ ត្រឡប់ះមើលងាយប្រមាថហា-



កាវិញ ហើយគេបទៅនៅទីងបងប្អូន ចាស់ទីងបងប្អូននៅតែម្នាក់ឯង ទៅជាឈឺតាប់ក្រោកពីកន្ទួលមិនរួចក្បែងផេះផ្ទះពេលយប់ អ្នកស្រុកគេទៅជួយមិនទាន់ស្លាប់កូនក្បែងរួចហើយបានយកខ្មោចទៅផុកយកឆ្អឹងទៅផ្ញើទុកឯវត្ត ។

ហ៊ុនសក្កាស្តាប់មាតានិយាយប្រាប់ចប់ ហេតុតែជាប់និស្ស័យបានជាប្តីប្រពន្ធ ក៏ផងខឹងតែក្តុកពុំបាន ប៉ុន្តែអាកយកធម៌មកពិចារណាសព្វគ្រប់ រូបំ ទុក្ខំ អនិច្ចំ អនត្តា " ក៏សាយសេចក្តីក្រោធក្លះកាល័យអស់ទៅ ។ ពេលនេះជាគ្រោះកម្មរបស់គេហើយ គេស្លាប់ទៅក៏ស្រួលដែរ បើប្រសិនរស់នៅ ខ្ញុំបាទដឹងថាគេប្រមាថម៉ែ ខ្ញុំបាទក៏មិនសូវសប្បាយចិត្តដែរ ។ ម្តាយថាអើការខុសត្រូវរកត្រាក់ល្អយ៉ាងណាបានមកជាកូនជាទៅហើយ ទីងកាត់ពាលម្តេចបាន តែនេះចិត្តរបស់អ អផ្តាច់ពីម៉ែ ម៉ែក៏មិនបណ្តេញទេ ស្រាប់តែចុះពីផ្ទះទៅឯង ។ លែងវិលមកលោកម៉ែ

សោះ លុះតែស្លាប់ទើបម៉ែដឹង ឥឡូវត្រូវកូនគិតធ្វើបុណ្យបន្តិចបន្តួចទទិសផលឲ្យទៅផងចុះ ។ កុំឲ្យអ្នកស្រុកគេនិន្ទាថាកូនឯងជឿស្តាប់តែ ពាក្យម្តាយ កាត់អាល័យប្រពន្ធនោះ ។

ហ្វូនសក្កាក៏អធិប្បាយជូនម្តាយស្តាប់ពីរឿង ទៅធ្វើពលការ ក្រោយពីបានឪពុកធម៌ម្តាយធម៌ប្អូនធម៌ដែលបានធ្វើជាស្នំឯក មានព្រះពជុរស ខ្លួនបានទៅច្បាំងឈ្នះសឹក-សត្រូវ នៅរលងឆ្នាំទើបបានវិលមកបន្ទាយលង្វែកវិញ មិនទាន់ដល់មួយខែលើកមហាកឋិនធំណាស់ បានសុំច្បាប់លោកមេទ័ពឲ្យតែបីអាទិត្យ ទឹងត្រឡប់ទៅវិញហើយ ថាខ្លួនខ្ញុំបាទធ្វើការបានកើតឈ្មោះ ព្រោះមានជ័យជំនះដោយសារតែគុណទឹកក្សីរមាតា ។ បានប្រសិទ្ធិពរឲ្យខ្ញុំបាទ ។ ក៏តាំងចិត្តគិតតតវេទី តបព្រះតេជៈព្រះគុណព្រះ-ករុណា ជាម្ចាស់ជីវិតលើត្បូង ។ ខ្ញុំបាទក៏បានទឹងទន្ទេញ



តាមប្រសាសន៍មាតា ទើបបានសម្រេចប្រយោជន៍ច្រើនយ៉ាង គឺប្រយោជន៍ ទី១ ខ្ញុំបាទបានបួនជបិជាគួប្រោសពេញទីទៅបមាតា មានព្រះពជុរសពេញទីមកុដកផកុមារគន់ទីងបានជាព្រះមហាក្សត្រយ៍សោយពជសម្បត្តិទៅ ឯផ្នែកប្រយោជន៍ទី ២ គឺខ្លួនខ្ញុំបាទបានឡើងយសសក្តិជាមេទាហានកាន់កូន ៥០០ រយ គឺមេរយ ងារជាហ្វូនសក្កា-វុធបុទ្ធិព្រៃ សក្តិ ៥ ហូពាន់ ។

តែនៅមានអកុសលឲ្យព្រាសនិកសប្រពន្ធ ។ ក៏មិនល្អនឹងអ្នកមាតាបើទុកជាមៅសើផកបណា ខ្ញុំបាទក៏ថយសេចក្តីស្នេហាស្រឡាញ់មិនស្មើដើមឥឡូវស្លាប់ទៅហើយក៏ជាដែរ ។

ហាគាព្វកូននិយាយក៏មានចិត្តរីករាយសប្បាយណាស់ តែថែមពីរកថា កូនបានដឹងរឿងអ៊ំ ដែលខ្មោចឪពុកបានភ្ជាប់និទានឲ្យស្តាប់ កាលអាយុអ្នកឯង ៦៧ ឆ្នាំ ថា

សេចក្តីគាប់គួរ ជាសត្រូវនឹងផ្លូវដែលមិនគាប់គួរ ព្រះម-ហាក្សត្រិយ៍រមែងជឿស្តាប់អ្នកនៅជិត ជាជាងអ្នកនៅឆ្ងាយ គុណទាំងឡាយមិនលែងក្លាយទៅជាទោស ហេតុនេះ កូនត្រូវប្រយ័ត្នរាំង កុំអាលត្រេកអរពេក បុរាណបាន តែងនិពន្ធទុកថា « កុំអរនឹងយស កុំខ្ញុកព្រោះថ្វស់ ទិ-កសកុំម្នេញ ខ្ចកកុំកុំដឹង ទឹងកុំខ្ទេញ មិត្រកុំកុំដេញ ស្អប់កុំ ព្យាបាទ ,, ។

ហ៊ុនសក្តាទទួលប្រសាសន៍ម្តាយ ហើយក៏សួរទៅទៀត ថា អាពាលវានៅឯណាទេ?

ម្តាយថា កាលប្រពន្ធកូនឯងនៅ វាតាមទៅនៅនឹងគេ វាមកឯណេះម្តង១ ដល់ប្តាស់ស្លាប់វាមកនៅនឹងម៉ែៗ តែវាមិនសូវនៅផ្ទះទេ ច្រើនតែទៅទាំឈ្លុស ទន្សាយ សំ-ពោច ត្រគួត នឹងសត្វឯទៀតៗ បានជាញឹកញយ ៗ បើសត្វណាធំពាំមិនរួច វាមកផ្ទះហៅក្មេងក្នុងផ្ទះ ឲ្យទៅ



តាមយកក្នុងព្រៃ ហើយវាច្រើនតែទាំបានពស់វែកវាកាយដីកប់ ៗ

លុះព្រឹកឡើងហ៊ុនសក្តាក៏ទៅសួរញាតិជិតខាង នឹងទៅថ្វាយបង្គំគ្រូ រួចហួសទៅសួរបងនឹងប្អូនថ្លៃប្រាប់ដំណឹងពីធ្វើបុណ្យឧទ្ទិសផលឲ្យទៅខ្មោចប្រពន្ធ ទៅប្រជុំគ្នានៅវត្ត ៗ អ្នកស្រុកនឹងប្អូនមានសេចក្តីត្រេកអរណាស់ ព្រោះដឹងគុនឈិនបានទៅធ្វើការបានឡើងយសសក្តិ ក៏នាំគ្នាចូលជួយធ្វើបុណ្យឯវត្តអស់ មួយយប់មួយថ្ងៃ ៗ នៅសំរាកបាន ១០ ថ្ងៃ ហ៊ុនសក្តាក៏លាមាតា គ្រូនឹងញាតិសន្តានវិលត្រឡប់ទៅឯបន្ទាយលង្វែកវិញ ដោយអាពាលទៅជាមួយផង ៗ

លុះមកដល់ស្រុកភ្នំពេញ ជាទីប្រជុំជនមួយ មានផ្ទះផ្សារលក់ដូរមនុស្សកុះករប្រហែលផ្សារកំពង់លួង ហ៊ុនសក្តាក៏រកផ្ទះសំណាក់បាន១ ឈប់ដេកនៅស្រុកភ្នំពេញ ។

## រឿងទី ១១

មានស្រីមេម៉ាយម្នាក់ឈ្មោះនាងម៉ារិន មានបុត្រី១អាយុ១៨ឆ្នាំ ពុំទាន់មានស្វាមី ឈ្មោះនាងគិនយ៉ាន់ រូបប្រផាន់ស្អាតល្អគ្រប់លក្ខណៈហើយចេះចំណេះអក្សរសាស្រ្ត ទៀតឆ្លាសជាងស្រីដទៃ ចំណេះនាងត្បាញរវៃដេរត្រើប ប៉ាក់ស្រេះ នាងក៏ចេះមុខម៉ាំ ៗ បិតាធ្វើការជាទៅ ក្រុមព្រះគាល័ក្ខ ផារជាប្រសើរអេក្កក ៗ លោកទៅ ក្រុមទូរ: អនិច្ចកម្មតាំងពីនាងគិនយ៉ាន់អាយុ ១៤ ឆ្នាំម្ល៉ោះ បិតានាងនេះមានប្អូនប្រុស ២ នាក់ ធ្វើការនៅទីទៅ ក្រុមសាលាខាងតុលាការនៅក្នុងផារ ៗ ឯនាងគិនយ៉ាន់ឈឺ រន្ទេផស្នាតើមកយូរថ្ងៃ ដាយកាបព្រោយរាធ្វើចុកពោះ ចេះតែយំ រូបតិយំទៅជាសើច ឬប្រៀន ម្តាយគេគ្រូមើលពុំជា ៗ ក្នុងវេលាយប់ដែលហ្វូងសត្វ ទៅឈប់សំណាក់ធាន ៗ ម្តាន់នាងនេះស្រែកយំផងប្រៀនផង ៗ ឯហ្វូង



សត្វកាលបើឮសំឡេងនាងគិនយ៉ាន់ស្រែកយំហើយប្រៀន ទឹកធ្លាក់ពេកក៏ក្រោកអណ្តើយហើយ ផ្សៀនស្តាប់កណ្តាលយប់ស្ងាត់កើតចិត្តប្រទេតករណាតន្ថតុក ទើបជាសម្ចាស់ផ្ទះដែលសំណាក់សួរថា «សំឡេងដែលប្រៀនផងយំផង នោះគឺអ្វី ?»

ម្ចាស់ផ្ទះប្រាប់ថា «កូនស្រីរបស់ខ្ញុំឈឺជាងមួយខែមកហើយចេះតែចុកពោះវេវរាយមិនដឹងខ្លួនទេ គេគ្រូមើលមិនត្រូវសោះ ៗ គ្រូហោរគេថាខ្មោចកាច ឬ ព្រាយរាធ្វើ គ្រូណាមកមើលរាស្តោះជាក់មុខគួរគេះដៀល ៗ ម្តាយរាប្អូនខ្ញុំបង្កើត ដូចជាតាល់ចំណេះទីងមើលហើយ ៗ អ្នកកូយមានចេះដឹងមន្តវិជ្ជាថ្នាំសង្កូវអ្វីខ្លះដែរ ? សូមមេត្តាអនុគ្រោះជាបុណ្យកុសល ខ្ញុំអាណិតណាស់ព្រោះម្តាយក៏មេម៉ាយ កូនដែលឈឺក៏នៅក្រមុំពុំទាន់មានប្តី ៗ

ប៉ុន្មានថ្ងៃមុននេះខ្ញុំនឹងម្តាយរាបានគេហោរទាយ គេ

ថាហ៊ានតែគ្រូឈ្មោះសុវណ្ណ ទើបមើលជា ខ្ញុំតាំងអស់គ្នា ប្រឹងដើរសួរគេឈ្មោះគ្រូសុវណ្ណមិនដឹងជានៅឯណា ចាល់តែនិគរកមិនឃើញ ហ្នឹងហើយនៅផ្សងព្រេងសិនចុះ ។

ហ្វូងសក្កាស្តាប់ម្ចាស់ផ្ទះនិយាយឲ្យនឹកចាំបានយល់សេចក្តី កាលនៅរៀនក្នុងវត្ត ព្រមទាំង ឃើញក្នុងសាស្ត្រាដែលរៀនផង ពាក្យសុវណ្ណគេប្រែថាមាស ខ្លួនអញនៅខេត្តបន្ទាយមាស អញទេដឹងដែលត្រូវមើល ជម្ងឺនាងនេះ? ណ្ហើយមើលយកបុណ្យទៅចុះ ។

ឯហ្វូងសក្កានេះ បានរៀនគម្ពីរជាច្រើនមុខហើយ ពូកែស័ក្តិសិទ្ធិណាស់ ៗ ព្រោះលោកគ្រូបានបង្រៀនកាលនៅវត្ត ៗ ទើបឆ្លើយថា ខ្ញុំបាទរៀនបន្តិចបន្តួចដែរ សូមអ្នកមីងជូនខ្ញុំបាទទៅមើលបន្តិចបានទេ ? នាងមិនអីទេក្មួយ ! នាងម្ចាស់ផ្ទះក៏នាំចុះទៅតាំងយប់ ៗ ទៅពេលដែលហ្វូងសក្កាចុះពីផ្ទះដល់ដី ម្ចាស់ជម្ងឺព្រឺខ្លួន



ញាក ហើយដូចជាមានខ្យល់តែមកពីចុង... សព្វាង្គកាយប្រមូលទៅនៅត្រង់ផ្ចិតកណ្តាល... សម្ងំស្ងៀមមិនថ្ងូរ មិនស្រែកសោះ ។

[stamp]

នាងម្ចាស់ផ្ទះសំណាក់ បាននាំហ្វូងសក្កាឡើងទៅលើផ្ទះប្អូនដែលកូនឈឺ ក៏ចូលទៅនិយាយប្រាប់ប្អូនថា «មានគេមកសំណាក់លើផ្ទះបង គេចេះមើលជម្ងឺ ឥឡូវបងនាំមកនៅអង្គុយល្វែងក្រៅ បងចង់ឲ្យគេចូលមកបន្តិច ប្អូនថាម៉េច ?

នាងតាំងពីក៏ចេញមក ៗ នាងម៉ានៃសំពះហើយថា សូមលោកមេត្តាអនុគ្រោះខ្ញុំម្តងចុះ ក្រែងកូនខ្ញុំមានព្រេងសំណាងមានអាយុជីវិតដោយសារគុណលោក !...

ហ្វូងសក្កាសំពះតបវិញ ហើយថា ខ្ញុំបាទមិនមែនជាគ្រូហ្មអ្វីប្រាកដទេ ៗ ចំណេះវិជ្ជាក៏រៀនល្មម តែជួយសង្គ្រោះញាតិក្នុងស្រុកផ្ទះជិតខាង ជួនកាលមើលទៅជា

កប ប្អូនកាលក៏មើលមិនជា តែពេលនេះខ្ញុំបានឮសំឡេងអ្នកឈឺថ្ងូរដល់ត្រចៀក ក៏មានសេចក្ដីអាណិតអាណោចខ្លោចចិត្តអត់មិនបាន បានជាខ្ញុំបានដណ្ដឹងសួរអ្នកមីងជាម្ចាស់ផ្ទះក៏បានដឹងរឿងនេះ .. នាងម៉ាឌែនក៏អញ្ជើញឲ្យចូលទៅក្នុងជិតល្វែងដែលនាងគិនយ៉ាំងដេក ឃើញអ្នកជម្ងឺនៅដេកស្ងៀម គ្រាន់តែក្រឡេកចុងភ្នែកមើលមកវិញហើយបែរមុខចេញ ។

ហ្វូងសក្កាដឹងច្បាស់ថា ជម្ងឺនោះប្រាកដជាមាបស្ដើ ហើយថា៖ សូមអនុញ្ញាតឲ្យខ្ញុំស្ទាបពាល់ខ្លួនអ្នកជម្ងឺបានឬទេ?

ម្ដាយឆ្លើយថា – បាន ! សូមលោកពាល់ចុះ...។

ហ្វូងសក្កា បានដកយកគ្រឡាប់ក្រមួនមកសែបគាថា ហើយយកក្រមួនលាបមេដៃចុចចំផ្ចិតសង្កត់បន្តិចទៅ អ្នកជម្ងឺក៏ស្រែកឆ្ងូរលើកដៃសំពះថា – ខ្ញុំកង់តាលខ្លាចលោកម្ចាស់ហើយ សូមឲ្យលោកអាណិតលើកលែងខ្ញុំទៅចុះ !



ខណៈនោះអ្នកជម្ងឺជាស្រឡះមុខមាត់ក្រោកអង្គុយ ស្រែកចកលើកបាយ ៗ នៅយប់នោះគេដេកលក់តាលភ្លឺ ដោយដឹងថាកាបនោះគេដោះរេះបាត់លែងនៅក្នុងស្រុកភ្នំពេញ ។

លុះព្រឹកឡើងហ្វូងសក្កា រៀបខ្លួនប្រុងនឹងលាម្ចាស់ផ្ទះចេញទៅក្រុងលង្វែក ចុលនាងម៉ាឌែនមកឃាត់ថា –សូមឲ្យលោកនៅបន្តិចសិន ព្រោះខ្ញុំកំពុងចង់ឲ្យលោកស្រោចទឹកដោះទបគ្រោះចង្រៃកូនខ្ញុំឲ្យបានសិន ឬលោកមានអ្វីដើម្បីទឹងដាក់បន្ទាំងក្នុងខ្លួនកូនខ្ញុំ កុំឲ្យខ្មោចបីសាចបៀតបៀនបានតទៅ ?... ម្យ៉ាងទៀតកូនខ្ញុំតាំងពីកើតមកមិនដែលឈឺធ្ងន់ដូចម្ដងនេះទេ ខ្ញុំនឹកថាក្រយុកគង់អស់ក្ដីគ្រានេះពុំខាន តែគឺកុសលសីលទានបានតឿនដាស់ឲ្យលោកស្ទុះមកជួយឧបត្ថម្ភ នាំឲ្យខ្លួនវារស់រានមានអាយុជីវិតដោយបុណ្យរបស់លោក ។ ខ្ញុំយល់ថា បើខ្ញុំលើកយកសម្បត្តិជាគ្រឿងឧបភោគទាំងអស់ បកតបស្នង

សងគុណលោកមិនជួន បើប្រសិនជាលោកមិនទាន់មានប្រពន្ធកូន ខ្ញុំក៏ហ៊ានលើកយកកូនខ្ញុំ ជូនឲ្យធ្វើជាភរិយា តែខ្ញុំមិនទាន់ដឹងអធ្យាស្រ័យលោកជាយ៉ាងណា ។ ខ្ញុំជាដោយគាត់អៀនខ្មាសទៅហើយ ទោះគេសើចយំយ៉ាងណាក៏តាមការ.. ។

ហ្វូងសក្កាក៏អង្គុយចុះឱនខ្លួនហើយនិយាយថាខ្ញុំបាទឈ្មោះគុងឈិន គ្មានប្រពន្ធទេ សព្វថ្ងៃធ្វើក្នុងពដការព្រះករុណាជាម្ចាស់ផែនដី នៅជាប់ក្នុងក្រុងលង្វែក ព្រះករុណាទ្រង់ប្រោសព្រះរាជទានឲ្យមាន ងារជាហ្វូងសក្កាវុធឫទ្ធិក្រមេតាហាន ស្រុកកំណើតនៅភូមិប្រាសាទ ខេត្តបន្ទាយមាស ទើបនឹងវិលមកពីសួរមាតាឯស្រុក បានមកឈប់ស្នាក់ត្រង់ទីនេះ ក៏ជាបុណ្យភ័ព្វឲ្យខ្ញុំបាទបានសង្គ្រោះអ្នកមីងនិងអ្នកកូនដែលឈឺ ។ ខ្ញុំបាទតាំងចិត្តមើលត្រង់សុចរិត គ្មានប្រាថ្នាគិតនឹងការផលប្រយោជន៍អ្វី សូម្បីតែ



បន្តិចបន្តួចក៏គ្មានក្នុងចិត្តសោះ ។ តែឥឡូវអ្នកមីងមកមានប្រសាសន៍ឲ្យទាល់តែលើសហួស មិនឲ្យខ្ញុំបាទរើខ្លួនរួចផុះ ក៏ឃើញថាជាការចំឡែកពេកណាស់ ។ ខ្ញុំបាទសូមប្រៀបចិត្តខ្ញុំបាទជូនអ្នកមីងស្តាប់ដោយសុចរិតថា «ដូចអ្នកបាក់គ្មានកាំពាក់ ដើរតែខ្លួនទទេ កាន់ប្រាក់ ១០ រៀលទៅរកទិញអាវដែលគេដេរស្រាប់ ទិញប្រញាប់នឹងកាលពាក់ទៅមើលបុណ្យនឹងគេ ។ តែគ្រប់ហាងតាំងអស់គេគ្មានអាវដេរស្រាប់សោះ បើអ្នកណាទិញគេឲ្យវាស់ខ្លួនជាមុន ទើបដេរជាក្រោយត្រូវនឹងខ្លួន កុំឲ្យខាតកំណាត់ផង ។ អ្នកនោះរកទិញពុំបាន នឹងព្រួយចិត្តណាស់ព្រោះស្អែកទៅបុណ្យ ទោះនឹងវាស់ដេរក៏មិនទាន់ បានដើរដិតផុតផ្សារ ទើបប្រទះហាងលក់អាវនៅតែមួយ និយាយថ្លៃត្រូវនឹងប្រាក់ដែលមាន លើកអាវមកល្បងត្រូវខ្លួនដូចគេវាស់គ្មានខុសបន្តិចសោះ អ្នកនោះក៏ទិញយកទៅដោយសេចក្តី

ក្តីអរយ៉ាងណា ខ្លួនខ្ញុំបាទអរនឹងប្រសាសន៍យ៉ាងនោះដែរ ។ ខ្ញុំសូមទទួលតាមប្រសាសន៍ជាប្រាកដ តែថាពេលនេះខ្ញុំបាទនឹងសម្រេចជូនសេចក្តីពុំទាន់បាន ព្រោះខ្ញុំបាទនៅមានមាតាជាទីគ្រប់គ្រងចាំ ខ្ញុំបាទទៅជំរាបសួរមាតាឲ្យព្រមផងទើបបាន . . . ។

ឆាងម៉ារែននិងបងនិយាយមកទៀតថា បើលោកក្មួយថាចាំទៅសួរមាតាសិនទើបស្រេចនោះ បើនឹងសង្ឃឹមថាជាប្រាកដក៏ពុំបាន បើមាតាយល់ព្រមផង ក៏ជាការស្រួលទៅចុះ បើមាតាមិនយល់ព្រមទេ នឹងជាម្តេចទៅវិញ? ។

ហ្វូងសក្កាថា — បាទ មិនមែនមាតាខ្ញុំនឹងមិនយល់ព្រមទេប្រាកដជាយល់ព្រមណាស់ !

ឆាងម៉ារែននិងបងថា យើងមិនជឿទេ សូមឲ្យសម្រេចត្រឹមខ្លួនលោកក្មួយទៅចុះ កុំឲ្យលំបាកទៅថ្ងៃមុខ !

ហ្វូងសក្កាថា — បាទការនេះសម្រេចត្រឹមខ្លួនខ្ញុំបាទ



ពុំបាន ខ្ញុំបាទចាំជំរាបមាតាសិន . , .

ឆាងម៉ារែនថា ឬលោកក្មួយមិនស្រឡាញ់កូនខ្ញុំទេ សូមឆ្លើយឲ្យត្រង់កុំវេស . . .

ហ្វូងសក្កា បាទ ! ខ្ញុំស្រឡាញ់ពេញចិត្តណាស់ ខ្ញុំបាទមិនមែនស្រឡាញ់តែត្រឹមរូបកូនម្នាក់នោះទេ គឺខ្ញុំបាទស្រឡាញ់ព្រមទាំងអ្នកមាតា ទីងអ្នកជាម្តាយជំអកខុសចិត្តបន្តិចសោះ ! . . . ។

ឆាងម៉ារែននិងបង បាននិយាយយាត់ហ្វូងសក្កាថា. ដូច្នោះ សូមឲ្យលោកក្មួយកាណត់បន្ទន់នៅទីនេះ ៣ ថ្ងៃទៀតសិមអញ្ជើញទៅស្រុកបន្ទាយ ដ្បិតយើងមានការជំរាបបងប្អូនពីរៀងនេះ នឹងឲ្យបងប្អូនគេមកស្គាល់រូបភាពលោកក្មួយផង ៖

អគមានយល់ទាស់សំដីស្រីមេម៉ាយតុងឈិន ក៏ឆ្លើយឡើងថា — បាទ ខ្ញុំបាទបន្ទន់បាន ៣ ថ្ងៃ ព្រោះមិនទាន់

ដល់កំហិតច្បាប់ ។

នៅក្នុងកាលនោះ នាងម៉ានៃក៏បានរៀបតាក់តែងផ្ទះ សំបែងជារបៀបដែលរៀបការ ហើយគាត់ទូកគំងមួយ ឲ្យមនុស្សបែរហែស ពីក្នុងពេញ ទៅបណ្តាយលង្វែកដើម្បី អញ្ជើញប្អូនទាំងពីរដែលផ្ញើទៅក្រម មកស៊ីការ នាងកិន យ៉ាន់នឹងហ្វុងសក្កា ។ ទូកក៏ចេញទៅមួយយប់ទាល់ភ្លឺ ដល់បណ្តាយលង្វែក ហើយអញ្ជើញប្អូនថ្លៃចុះទូកមកស៊ី ការក្មួយ ។

## វគ្គទី ១២

ខណៈដែលហ្វុងសក្កា សុំច្បាប់ទៅសួរមោកាឯខេត្ត បណ្តាយមាស ក្រោយនោះ ៣ ថ្ងៃ ហ្វុងព្រះកមាធិបតី ទ្រង់ទឹកលើកព្រះរាជទារស ដែលទើបកើតពីផ្ទៃមាតា ដលទិត្យសុវណ្ណ មានព្រះតម្រាសឲ្យស្រីព្រះស្នំពៅទៅ អញ្ជើញព្រះទេពីនេះ ឲ្យយកព្រះរាជកុមារទៅថ្វាយ ព្រះ



ទេពីក៏ពរព្រះរាជទារសចូលទៅថ្វាយដល់ព្រះថែនខាងក្នុង ព្រះរាជកុមារកាន់ស្នៀតសក់ព្រះមាតាលេងជាប់នឹងព្រហស្តព្រះ មាតាក៏ក្រូចមិនបានយកចេញ ។

ព្រះករុណាទទួលព្រះរាជទារសយកទៅទ្រលើកឡើង ហើយថើប ១ ហើយលើកសួយថាកូននេះធាប់មានព្រលឹង ថ្លាស ដៃជើងក៏ធំប៉ុនបែបជាអ្នកខ្លាំង ឯងធំឡើងផ្ញើមេ ទ័ពទៅច្បាំងយកនគរស្រីអយុធ្យាឲ្យបានចុះ ។

ព្រះរាជកុមារកាន់ស្នៀត ព្រះហោលីជាប់នឹងព្រះ-ហស្តក្រវីក្រវាសទៅមក ចុងស្នៀតព្រះហោលី ស្រួច ដូចចុងដែកគោល ដូចគេចុកបន្តិចទៅត្រូវព្រះនលាដ៍ ព្រះបិតាចេញព្រះលោហិតសើមៗ មានតម្រាស ថា កូននេះកាចណាស់ហ៊ើយ ចុកថ្ងាសអញ ហើយព្រះមាតា ក្រឡេកឃើញក៏ស្លុតព្រះទ័យណាស់ គញ្ជាក់យកព្រះកុមារ មកទះគ្រៀក ១ ដៃ ព្រះរាជកុមារទ្រង់ព្រះកន្សែង

ដោយភ័យនឹងកញ្ចាក់ខ្លាំងផង ឈឺនឹកខឹងខ្លាំងផងព្រះករុណាស្រែកគំហកឲ្យព្រះទេពីថា នាងឯងមិនត្រូវយកក្មេងតូចប៉ុណ្ណឹងខ្លាំងដូចជាយមនុស្សធំដូច្នេះទេ ក្មេងប៉ុណ្ណឹងវាដឹងអី ឯងចាស់គតគំនិតបណ្តោយឲ្យវាកាន់របស់ស្រួចលេង ខុសលើខ្លួនឯងមិនដឹងទេ ឬ ?

ត្រាស់ហើយក៏លើកព្រះកុមារទៅពារវិញ ឃើញស្នាមដាំក្រហមតាមម្រាមដៃ ព្រះអង្គក៏ទ្រង់ល្អួងអង្អែលពាល់តែព្រះកុមារបាត់ទ្រង់កន្សែងរើបលេងសប្បាយដោយពួកកិលៀង ៗ ឯស្នាមនៅព្រះទណភ័ ក៏ហើមបន្តិច ៗ

ខណៈនោះស្រីព្រះស្នំដែលទទួលផ្ញើពីសម្តេចចៅហ្វាទលហៈ ចាត់ឲ្យស៊ើបយកការកំហុសរបស់ចៅចបមាតដល់ចិត្តស៊ីវណ្ណជាតិនត្តលុះឃើញថា ចៅចបនេះធ្វើសប្រហែស បណ្តោយឲ្យព្រះរាជកុមារកាន់របស់ស្រួចគ្រោះគ្រវាយត្រូវព្រះឧលាដ៏ព្រះមហាក្សត្រដូច្នោះ ក៏ប្រញាប់ស្ទុះ



ជំនិតឲ្យចេញទៅជំពបសម្តេចចៅហ្វា តាមប្រវត្តិហេតុ ឯសម្តេចចៅហ្វាបានដឹងដូច្នោះ ក៏ពេញអំណរណាស់ លុះព្រឹកឡើងក៏សុំអនុញ្ញាតចូលគាល់ព្រះមហាក្សត្រ ទំនងក្នុងជាការសម្ងាត់ខាងផែនដី លុះចូលទៅក្រាបបង្គំហើយ ក៏ទូលបញ្ជិតបញ្ជៀងពោលទោសពីពួកសេនាទាហាន ដែលលើកទ័ពទៅច្បាំងនៅទីឯណា ប្រើតែទៅធ្វើដណ្តើមយករបស់ទ្រព្យអ្នកស្រុកពីព្រោះមេទ័ព នឹងសេនាទាហានធំ ៗ បណ្តោយឲ្យកូនទាហាន ទើបកើតចលាចលក្តៅក្រហាយដល់ការណាប្រជានុរាស្ត្រ ៗ

ព្រះករុណាទ្រង់ព្រះសណ្តាប់ទើបត្រាស់ថា ចាំទ្រង់នឹងស្តីលើកទុកញាតិជ័យ សង្គ្រាមមេទ័ពឲ្យប្រដៅកូនទាហាន លុះចូលរឿងនេះអស់ហើយ សម្តេចចៅហ្វាក៏ធ្វើជាងើបឡើងសំឡឹងព្រះភក្ត្រព្រះករុណា ហើយធ្វើជាទូលថា ព្រះករុណាមានស្នាមអ្វីនៅនឹងព្រះឧលាដ បានដូចជាគេហើម

បន្តិច ព្រះករុណាក៏ទ្រង់ត្រាស់តាមត្រង់ ពីរឿងព្រះរាជកុមារកាន់ស្បៀតមោលីក្រវ៉ាសត្រូវហើយជាបន្តិចបន្តួចទេ ។

សម្តេចចៅហ្វាទូលថា ព្រះករុណាត្រាស់ជាតិចនេះមិនចំនង់សោះ នេះជាពេលដែលព្រះអង្គទ្រង់នៅមានអភិនិហារបារមី បើមិនអ៊ីនឹងត្រូវព្រះនេត្រអន្ធការទេឬ ខ្ញុំព្រះអង្គយល់ថា ព្រះទេពីធ្វេសប្រហែសហេតុ សូម្បីទឹកចិត្តក៏មិនមែនត្រង់ល្អនឹងព្រះករុណាប៉ុន្មាន នឹងជាឧបាយយកកលក៏បាន ព្រោះការឃុំគ្រងកេរ្តិ៍ព្រះមហាក្សត្រជាម្ចាស់ផែនដីនេះ លោកឲ្យប្រុងប្រយ័ត្នកុំធ្វេសឬមានគ្រោះថ្នាក់សូម្បីតែមុតដោយបន្លាតូចដូចចុងម្ជុលក៏ពុំបាន សុទ្ធតែទោសនៅលើអ្នកក្រអង្គទាំងអស់ ឥឡូវព្រះទេពីប្រមាថការដូច្នេះចូលក្នុងបទព្រះអយ្យការជាមហន្តគួរនឹងធ្វើទោសផ្ចាល កុំឲ្យមនុស្សឯទៀតយកតម្រាប់តាមបើទ្រង់នឹងលើក មានតែត្រូវលុបមហាព្រាក្នុងក្រុមមន្ទីរពាល ត្រង់ភាគដែលបញ្ញត្តិពេតិច្ច



ដែលក្សត្រអង្គនោះកុំឲ្យមាន បើមិនឲ្យមានមហាគ្រាត្រង់នេះហើយ អស់អំណាចព្រះមហាក្សត្រយ៍ក៏នឹងបាត់ទៅ គ្មាននរណាខ្លាចអម្ចាស់ផែនដី ។

ន័យមួយទៀត ព្រះរាជកុមារពិតតែនៅតូចជាព្រះរាជយោវ មិនទាន់ដឹងសេចក្តីក៏មែន តែបេញព្រះផ្លូឲ្យឃើញថា ជាគ្រូប្រទូស្តរាយដល់ព្រះអង្គ ៗ ទ្រង់ជ្រាបតាមរបៀបរបាព្រះរាជពង្សាវតាព្រះមហាក្សត្រិយ៍ពីបុរាណ ជាគូសត្រូវនឹងមិត្ត ជាសត្រូវនឹងបុគ្គលប្រទេស បើមិនប្រទេសនេះ ក៏ប្រទេសនោះ គួរតែព្រះអង្គនឹងធ្វើទណ្ឌកម្ម ឬបញ្ជូនទៅយកបម្រើនាឧមិនបាន ។

ព្រះករុណា ទ្រង់ព្រះសណ្តាប់ក៏ជួចជាស្តុតព្រះទ័យ តែនៅហានមានថា រាជកុមារនៅតូចមិនដឹងទេ ឯទេពីក្សត្រីតែងធ្វើ គ្រាន់តែចូលក្នុងសេចក្តីធ្វេសប្រហែសនោះមែន បើនឹងធ្វើទោសក៏មិនជាយុត្តិធម៌ ។

សម្តេចចៅហ្វាទូលថា “ បើព្រះអង្គទ្រង់ឃើញថាព្រះទេពីធ្វេសប្រហែសមែនហើយគួរ ឬ មិនគួរត្រង់បទក្បួនអគ្គព្រះបទមាត្រានោះថាធ្វើដោយក្លែងក៏ទោស ឬ ដោយមិនក្លែងក៏ទោសជាមហន្តដូចគ្នា ប្លែកតែស្រាលនឹងធ្ងន់ប៉ុណ្ណោះគ្មានបទឲ្យលើកលែងទេ ” ។

ព្រះករុណាដូចជាតាល់ព្រះតម្រិះនឹងដោះសា ព្រោះទ្រង់ជ្រាបថា មាត្រានោះពោលដូច្នេះមែន ក៏មានព្រះតម្រាស់ថា “ បើដូច្នេះ លោកយល់ឃើញដូចម្តេចជាការសមគួរ ? ”

សម្តេចចៅហ្វាទូលថា “ គួរណាស់ត្រឹមឃុំខ្លួនទុកក្នុងគុក សំរាប់ត្រៃពេជ្រវាំងមុនឲ្យព្រះបរមពេជ្រវាំង ។

ព្រះករុណា ត្រាស់ហើយក៏ចូលទៅខាងក្នុងប្រាប់ទៅបមហាតថា “ ខ្ញុំនាងឯងនេះមានទោសតាមព្រះអយ្យការ ក្រមមន្ត្រីបាលត្រង់បទក្បួនអគ្គ សម្តេចចៅហ្វា គេ



មកទូលសុំហ្វូងឲ្យសម្រេចទោស ព្រោះនាងឯងធ្វេសប្រហែសឲ្យកូនកាន់ឈើស្រួច គ្រវាសត្រូវថ្ងាសយើង ១ នឹងអាស្រ័យក៏ខុសពីគតិច្បាប់ ហើយនាងក៏ពុំតូបចិត្តត្រូវទទួលកម្មឲ្យរួចទៅចុះ ហ្វូងមិនទោលឯងទេ ព្រះទេពីដូច្នោះក៏ស្ទុះក្រពលឹងដួលចុះហើយយំទូចព្រះបាទព្រះករុណាទូលថា “ ខ្ញុំម្ចាស់មិនដឹងថាខ្លួនធ្វេសប្រហែសមែន តែខ្ញុំម្ចាស់មិនមែនក្លែងធ្វើដោយចេតនាសព្វថ្ងៃបានមកជ្រកកោនក្រោមម្លប់ព្រះបរមពោធិសម្ភារព្រះបារមី ក៏បានសេចក្តីសុខហូតដល់គោត្រត្រកូល ខ្ញុំម្ចាស់គ្មានចិត្តគិតវៀចទុច្ចរិត ឬប្រមាទមើលងាយព្រះបេស្កាល្អផូលី មានទីសង្ឃឹមថាខ្លួននឹងបានសុខដោយសារព្រះបារមី លុះដល់ថ្ងៃស្លាប់ ពុំបានដឹងថាខ្លួនខ្ញុំម្ចាស់អភ័ព្វធ្លាក់ដល់ទីនេះសោះ ។

បើព្រះអង្គទ្រង់នឹងយកទោស ខ្ញុំម្ចាស់ពីព្រោះធ្វេសប្រ

ហេតុដូច្នេះពីម្សិលមិញគួរតែ ទ្រង់នឹងសម្រេចទោសតែម្តង កុំឲ្យខ្ញុំម្ចាស់ជឿខ្លួន ថា ខ្លួនមិនមានទោសភ័យ ។ អ្នកដទៃ ដែលចាំផ្ទាឈ្មោះ គេមិនសូវផ្តន្ទាថែមជាប៉ុន្មានព្រោះ បានសុខមកហើយ ម្តេចឡើយត្រឡប់ឲ្យជាប់ជាទុក្ខទៅវិញ ក៏ជាកម្មអភ័ព្វពេកណាស់ ឬព្រះករុណា តាមគេដំរះញុះ ញង់ ព្រះអង្គមិនទ្រង់អាណិតអាសូរខ្ញុំម្ចាស់ខ្លះទេឬ បើ មិនទ្រង់ព្រះមេត្តាតែត្រឹមខ្ញុំម្ចាស់ដែលធ្វេសប្រហែសខុសចុះ ព្រះរាជកុមារព្រះអង្គទ្រង់នឹងកាត់កាលមិនអាណិតទៅដែរ? ព្រះនាងក៏តែតែយំទូលព្រះបាទា ព្រះរាជកុមារក៏ទ្រង់ព្រះ កន្សែង ពួកស្រីស្នំក្រមការក៏សោកយំពេញព្រះរាជវាំង ។

ហ្លួងព្រះពលាធិបតីក៏ក្តួលព្រះ ទុកទឹកអាណិតព្រះទេពី និងព្រះរាជកុមារពន់ពេកណាស់ តែមានព្រះទ័យនៃក្សត្រិយ៍ ដែលបានចេញព្រះវាចាទៅហើយ ក៏ទ្រង់បង្ខំព្រះទេវីនេះឲ្យ ទៅខាងក្រៅ ព្រះនាងក៏ពព្រះរាជកុមារចេញទៅ ។



សម្តេចចៅហ្វាទលហៈ ក៏ហៅទាំងហ្លួងកប្រុកឲ្យយក ទៅថមហាគា ផលទិព្វសុវណ្ណទឹង ព្រះរាជទេវី ព្រះជន្មវស្សា ទើបបាន១ឆ្នាំនោះទៅដាក់គុកងងិត ក្នុងកំផែងព្រះបរមរាជ វាំងតាំងពីថ្ងៃនោះមក ។

## វគ្គទី១៣

នាងមាឡែនបានជួបជុំក្រុមញាតិ ព្រមទាំងប្អូនថ្លៃ២នាក់ ដែលធ្វើចៅក្រមសាលា បានពិគ្រោះគ្នានឹងលើកនាងគិន យ៉ាន់ ជាបុត្រីឲ្យហ្លួងសក្តា កុំឲ្យប្រុសនេះដឹងខ្លួន តែ មុននឹងរៀបវិវាហមង្គល នាងមាឡែនបានទៅបញ្ជាក់សួរចិត្ត បុត្រី ថានាងនេះនឹងព្រមស្ម័គ្រចិត្តស្រឡាញ់ហ្លួងសក្តាដែរ ឬទេ ?

នាងគិនយ៉ាន់ឆ្លើយដាក់ឧបមាការពីក្តាយពុំនឹងមានថា "ខ្លួនរបស់ខ្ញុំនៅក្រោមបង្គាប់មាតាក៏មែន តែបើចិត្តរបស់ ខ្ញុំពុំគាប់អធ្យាស្រ័យត្រង់ណា ខ្ញុំក៏ត្រូវដាក់ឧបមាតាឲ្យជាទំពិ

ទារុណ ។

តែវេលានេះខ្ញុំយល់តាមមាគា ព្រោះត្រូវអធ្យាស្រ័យ របស់ខ្ញុំពុំមានទាស់ គឺជាខ្លួនខ្ញុំតាំងពីដំបូងក្ដីហើយ សូម្បី បុរសដែលស្រករគ្នា ក៏ពុំដែលមាននរណាកាន់ពាល់សាច់ ខ្ញុំ ពេលនេះហ្លួងសក្កាបានកាន់ពាល់ខ្លួនខ្ញុំ កាលជម្ងឺឈឺ ទម្ងន់នោះ ។ ខ្ញុំដឹងកំឡាំងខ្ញុំច្បាស់ ថាគង់ស្លាប់ក្នុងយប់ ដែលអ្នកនេះទៅមើលខ្ញុំជា ខ្ញុំមានអំណរណាស់ដែលមាគា លើកខ្លួនខ្ញុំឲ្យជាភរិយាអ្នកនេះត្រូវអធ្យាស្រ័យខ្ញុំហើយ ។

ចៅក្រមពីរនាក់ជាប្អូនថ្លៃនាងម៉ារីន ក៏ឆ្លើយឡើងថា ហ្លួងសក្កានេះ យើងក៏ឮនាមឈ្មោះជាសេនាក្នុងបុរាំង មានតាំងប្អូនស្រីម្នាក់បានធ្វើជាព្រះស្នំឯកក្នុងហ្លួង ក្រោយ ឡើងជាចៅបមមាគាផលចិត្តសុវណ្ណ ព្រោះមានព្រះរាជ ទរស ១ ជាទីសំឡាញ់ ព្រះករុណា ព្រះជន្មទើបបាន ១ ឆ្នាំ ឥឡូវលោកសម្ដេចចៅហ្វា ទៅញុះញង់ឲ្យហ្លួងយក



ទៅដាក់គុកងងឹត ព្រមទាំងមាគានិងបុត្រ ព្រោះថាអាការ ធ្វេសប្រហែសឲ្យបុត្រកាន់ស្នៀតសក់ ក្រីក្រាសទៅ ត្រូវព្រះឧលាដ៍ព្រះរាជាមុតបន្តិច ។

នាងម៉ារីនសួរប្អូន «ត្អូនលាដ៍នោះ ?

នាងម៉ារីនថា «ថាសហ្លួង»

នាងម៉ារីនថា «យើហ្លួងអាចម៉េះ ! កូនគូបព្រះ ជន្ម ១ ឆ្នាំប៉ុណ្ណោះពុំទាន់ដឹងអី ម្ដេចក៏យកម្ដាយកូនទៅដាក់ គុកជុំនម៉េះ »

ប្អូនថ្លៃថា "ហ្លួងនេះទ្រង់ធម៌ល្អណាស់ តែព្រះ ស្រោត្រចង់ស្រាលបន្តិច បើកុំតែសម្ដេចចៅហ្វាទៅញុះ ញង់គ្មានអីសោះ ច្បាប់មន្ទីរព្យាបាលមានបញ្ញត្តិមែនហើយ តែមានក្នុងបទព្រះធម្មនុញ្ញបញ្ញត្តិកាសសំដែងថា ទោស ឯណាដែលប៉ះទៅលើព្រះរាជវង្សានុវង្ស ដែលត្រាប់តាប់ព្រះ អធ្យាស្រ័យហើយធ្វើខុសដំបូង នរណាមិនទៅដែនព្រះ

រាជហឫទ័យ ដែលទ្រង់ព្រះតំរិះយល់ឃើញពីព្រ អង្គឯង មិនបាន បើទំនួលឲ្យព្រះមហាក្សត្រយល់តាម ទុកជា អ្នកទោ ដណ្ដើមអំណាចនេះ សម្ដេចចៅហ្វាគានខ្លួនលោក ជាគ្រូហ្លួង បានជាចេះតែញុះហ្លួងតាមអំពើចិត្ត តាម សង្កេតមើលទៅដូចជាប្រុងចង់ដណ្ដើមទីចៅចមទេដឹង លោកចៅហ្វានេះ លោកខ្លាំងណាស់»

នាងម៉ារិនថា «ណ្ហើយលោកប្អូនកុំប្រាព្រួយរឿងគេ យើងគិតតែរឿងយើង ឥឡូវបងគិតដូច្នេះ ព្រោះហ្លួង សព្ទាប្រកាន់គុណមាតាខ្លាំងណាស់ ជាប់មិនដកបមាតាជា មុនទេ ទោះបីយើងបង្ខំយ៉ាងណាក៏នៅជាមិនព្រម ហេតុ នេះយើងបង្ខំមិនបានទេ ចិត្តបងយល់ឃើញព្រឹកនេះ យើង រៀបចំខ្លួនកូនស្រី ឲ្យទៅក្រាបសំពះមេបាមាមីងហើយ យើងសំបូងសម្រែនសែនលើកដល់ដូនតាតាសំទុំតាមទំនៀម ស្វាត់ ៗ ជាយើងបានលើកកូនយើងឲ្យដាច់ស្រេចទៅជា



កៀយហ្លួងសព្ទាហើយ កុំឲ្យដូនតាទឹងដំតាស់ដទែង ឯ សាមីខាងប្រុសយើងកុំឲ្យដឹង ឲ្យវាទៅឯផ្ទះបងដែលសំ ណាក់ទៅចុះ ដល់ពេលយប់យើងរៀបលៀងភាហារសម ហៅសាមីខ្លួនវាមកស៊ីលៀងជាមួយ ទីងយើងរួចសមគិតទៅ ទៀត» ។.

ប្អូនថ្លៃប្រុសពីនោកនឹងយល់ព្រមៗ បងស្រីហើយប្អូនស្រី ចាំងពីថា «ខ្ញុំពេញចិត្តណាស់នឹងឈ្មោះនេះ បើអ្នកបងចាក់ យកមិនបាន ដូចខ្ចប់សោភាជានេយ្យដ៏វិសេស ១ អ្នក បងក្រទំគិតឲ្យមែនទែន ដូចពុកណាថា «បើនឹងបាបឲ្យ បានផ្កាមាត់» ឬថា «បានមាសក្រឯក្រជាសរប» ។

លុះព្រឹកឡើងនាងម៉ាលីនបងប្អូន ក៏បានរៀបការ បុត្រីជាស្រេចដូចខាងលើនេះ ហើយមិនឲ្យហ្លួងសព្ទាដឹង ផងសោះ លុះវេលាល្ងាចក៏រៀបភាហារលៀង ហើយ រៀបចំកន្លែងបុត្រីទុកជាស្រេច ។

ដល់ម៉ោង ៧ យប់ នាងម៉ារិន ក៏ទៅអញ្ជើញហ្វូងសត្វា ឲ្យទៅស៊ីល្បៀង ជាមួយមីងខ្លួនហើយនឹងបងប្អូន ព្រមទាំងខ្លួននាងកិនយ៉ាន់ រួមគ្នាៈ ១ អង្គុយកៅអីគ្នា ៦ នាក់ ។ កាលហ្វូងសត្វាឡើងទៅលើផ្ទះ នាងម៉ារិន ចង្អុលប្រាប់ថា ២ នាក់នេះ ជាប្អូនថ្លៃបង្កើត ផ្ញើទៅក្រុមសាលាហ្វូងសត្វាក៏សំពះគំនាប់តាមគួរសម ហើយក៏អង្គុយរួមគ្នាជាមួយគ្នា ម្តាយក៏ហៅកូនស្រីឲ្យមកអង្គុយខាងស្តាំហ្វូងសត្វា ហើយក៏បរិភោគអាហារ ហ្វូងសត្វាក៏មិនហ៊ានបែរមើលស្រី ។ ក៏មិនហ៊ានបែរមើលប្រុស ម្តាយនឹងមាក៏នាំគ្នានិយាយលេងកំពុងបាយ ដើម្បីឲ្យបាត់ខ្មាសអៀន តែមាមានអធ្យាស្រ័យគិតថា បើនឹងឲ្យដំណឹងពីចៅចមជាប់គុក មុខជាហ្វូងសត្វាស៊ីបាយមិនពេញពោះ ម្ល៉ោះហើយក៏នៅចាំទាល់តែជិតឆ្អែត ទើបបង្គាប់ឲ្យនាងកិនយ៉ាន់ចាក់ស្រា (តារណូរ) ដែលហៅថា កប់សេន



វិញពីស្រុកស្វាតសិដ្ឋបូរ ចាក់គន្ទេះកែវតូច បំពងឲ្យលាយស្ករ ឲ្យនាងនេះលើកហុចទៅហ្វូងសត្វា ។ ក៏ទទួលហើយដាក់លើតុ លើកដៃសំពះមាតាទាំងមាហើយ « ខ្ញុំបាទសុំទោសចុះ ព្រោះខ្ញុំបាទមិនដែលទទួលទានស្រា តាំងពីកូនមកនឹងទទួលទានមិនបានទេ ខ្លាចស្រវឹង »

មាថា « នេះមិនមែនស្រាទេ គឺជាគ្រឿងទេសថយ៉ាងល្អទី ១ ប្រទេសអឺរ៉ុបគេកប់កានទទួលទានឲ្យលាយអាហារ បើតាមធម្មតាគេប្រើគ្រាលាយស្ករស ២ ឬ ៣ ដុំ ផ្សំនឹងទឹកដម្រង់ដែលថ្លាស្អាត ហើយទទួលទានមុនពេលបាយប្រហែល ១ ចំអិនបាយទើបល្អ តែនេះខ្ញុំមិនឲ្យលាយ កុំឲ្យរាសាបកំឡាំងក សុំឲ្យលោកក្មួយពិសារទៅចុះ បើមិនបានច្រើន តែបន្តិចក៏បានដែរ កុំឲ្យគេអួតជួនអៀនដៃ ,, ។

ហ្វូងសត្វាឮដូច្នោះ ក៏គួរសមដល់នាងកិនយ៉ាន់លើកកែវស្រាកាន់ហើយនិយាយថា « ខ្ញុំបាទសូមទទួលទាន

នេះទុកជាលើកដល់លោកតាំងអស់ ដែលខ្ញុំបាទចេញពីមួល ទានអាហារជាមួយ ទុកចំណាំជាទីគាប់អានយ៉ាងខ្ពស់បំផុត ព្រោះខ្ញុំបាទពុំដែលបានសេពសោះ សុំឲ្យចិត្តខ្ញុំបាទ នៅជាប់សប្បុរសដូចសព្វថ្ងៃនេះ កុំឲ្យសាបរលាបទៅវិញ ជាហើយក៏លើកស្រានោះ ផឹកចូលទៅក្នុងបំពង់កប្រហែល ១ ពែងកាកោ សេពណាក៏ផ្អែមឈ្ងុយនៅក្នុងមាត់ ស្រានោះខ្លាំងពេកណាស់ មិនមែនស្រវឹងហ៊ើសដូចស្រាចិនទេ ប្រហែលមួយ ចំពោះស្នាល្អិត ទើបរាវចេញពិសស្រៀវៗ ឲ្យមុខនោះក្រហមៗ តាំងស្លឹកត្រចៀកនិងថ្ពាល់ក្ដៅផ្ទុកជម្ពូ ។

ទៅក្រោម ២ នាក់យល់ថាហ៊ុនសត្តាស្រវឹងស្រា បានការហើយ ក៏ប្រាប់ព្រឹត្តិរឿងទៅចមហាគាជាប់គុក ដោយសម្ដេចចៅហ្វាញុះញង់ ហ៊ុនសត្តាស្ដាប់ចប់ក៏ជ្រះចង្អើសគឺដៃ វិស័យដូចគេយកកាំបិតមកវះយកថ្លើមប្រមាត់ បាក់



ស្នាតើ ក្រាបលើគុបាន ១ ស្របក់នើបឡើងទៅជាស្រក់ទឹកនេត្រា ណាទឹកកាណិតទៅចមហាគានិងព្រះរាជកុមារ ណាទឹកខ្លាចផ្សាក្ដៅចិត្តនិងសម្ដេចចៅហ្វាទលហៈ ក៏លាន់វាចាថា ម៉ែះហើយខ្ញុំបាទស៊ូចង់ហេតុគ្នា និងសម្ដេចចៅហ្វាក្រោកែព្រះធរណីគ្រប់មុខ ឯចៅចមហាគានិងព្រះរាជកុមារ ខ្ញុំបាទក៏គស៊ូបរខ្លួន បូជីវិតមិនឲ្យលោកទៅរងទុក្ខក្នុងគុកងងឹតដូច្នោះឡើយ ។

នាងម៉ាវិទ ឮ ហើយឆ្លើយឃាត់ថា „លោកកុយកុំព្រួយពិបាកក្នុងចិត្តធ្វើអី ធម្មតាមនុស្សយើងក្នុងលោកិយរវែនដូចភ័យវិបត្តិស្មើគ្រប់គ្នា លោកកុយកុំភាលទិនចងពៀរវេរាទិនគេ ដែលគេធ្វើយើងដូច្នេះយើងជាប្រុសដើមប្រុង ៤ ហត្ថត្រូវចេះគិតរំលត់កំហឹង ប្រើងកែប្រាជ្ញាទិនជួយដោះចៅចមហាគា និងព្រះរាជកុមារទៅល្អជាង" មួយយ៉ាងទៀតលោកថា „ស៊ូបកុំញាបាទ ,,

ហ្វូនសក្កា ៗ នាងម៉ារីនេថាដូច្នោះ ក៏នឹកគ្រាន់អន់ចិត្តបន្តិច ហើយថាប្រសាសន៍អ្នកមីនដូចគ្នា នឹងប្រសាសន៍ខ្ញុំបាទចំណែកខ្ញុំបាទទទួលស្តាប់មិនកើតទេ ។

ឯសេចក្តីដែលហ្វូនសក្កាឈឺចិត្តក្តុងរឿងនេះ ដោយសំណាបសុកបណ្តាលឲ្យស្រវឹងវង្វេង ក៏ភ្លេចគិតសោះ លើកកែវពារណ្តៅទាល់តែអស់ចំនួនប្រហែល ៣ កែវ ពេងអាគោគួបទៅនៅក្នុងពោះ តែមនុស្សនេះមានកំឡាំងខ្លាំងណាស់ មិនគង្វះអន្ទុងគ្រាន់តែស្រវឹងជ្រប់ស្មារតីគ្រាបទៅលើតុ ។

លោកចៅក្រម ១ នាក់ ឃើញបានការហើយ ក៏លាបង់ថ្លៃទឹកឃ្មុំឲ្យតៅកែ សុំឲ្យចំរើន ។ ហើយពុះទូកវិលទៅលំនៅផ្ទែកតាំងយប់ ដើម្បីឲ្យទាន់ពេលឡើងសាលាក្តី វេលាព្រឹកឡើង ។

នាងម៉ារីនេនឹងបងស្រី ក៏ឲ្យមនុស្សជួយលើកខ្លួនហ្វូនសក្កា



ទៅដាក់លើគ្រែនាងកិនយ៉ាំងដេក ហើយពន្យល់ឲ្យនាងនេះទទួលព្រមលួមរួមដំណេកជាមួយនឹងហ្វូនសក្កា ។

ប្រហែលម៉ោង ៩ ឬ ១០ យប់ នាងម៉ារីនេក៏ឲ្យមនុស្សប្រុសបំពងតាលែតភ្លើងដេកលក់តាំងអស់គ្នា ឯនាងកិនយ៉ាំងក៏លបចូលទៅដេកលើគ្រែខាងស្តាំទន្ទឹមគ្នា តែមិនហ៊ានទិតទៅជិតឲ្យពាល់ប្រទះខ្លួននឹងគ្នាសោះ ព្រោះនឹកខៀនខ្មាសណាស់ ។

ហ្វូនសក្កាស្រវឹងស្រាខ្លាំងណាស់ ព្រោះមួយអាយុបកហើយមិនដែលផឹកស្រាសោះដេកសន្ធប់មិនដឹងខ្លួនការលគេលើកមកដាក់លើគ្រែក៏មិនដឹង លុះដល់ពេលផាសុំមាន់រងាវម្តង បង្អួចបើកពីខាងមានសន្សើមបក់អណ្តែតភាយខ្យល់ចូលតាមបង្អួចទៅប៉ះលើខ្លួនហ្វូនសក្កា ឯឬទ្ធិស្រាដែលស្រវឹងក៏សាបរលាបអស់ទៅ ហ្វូនសក្កាប្រែខ្លួនដឹងស្មារតីក្រឡេកមើលកន្លែងដេកខុសចំណាំ មើលទៅ

ខាងស្ដាំឃើញច្បាស់ជាមុខនាងកិនយ៉ាន់ដេកប្របខ្លួន ក៏ឲ្យមានចិត្តភិតភ័យណាស់ ដែលមើលស្គាល់ច្បាស់ព្រោះតាមនៅក្បែរនេះរឹម ៗ ក៏នឹកបានជាគេបញ្ឆោតខ្លួនឲ្យជាប់សេចក្ដីសុខៈ ដែលកតញ្ញូនឹងមាតា ឯសេចក្ដីដែលស្នេហាស្រឡាញ់នាងកិនយ៉ាន់ ក៏សែនស្រឡាញ់ពេញប្រកិត្ត ដោយប្រពន្ធស្លាប់ព្រាត់ទៅជិត ៤ ឆ្នាំ នៅតាំសេចក្ដីដែលស្រីនឹងបុរសរួមសម្ភសនឹងគ្នាជាទីសប្បាយយ៉ាងណា ក៏ជួបនឹងសេចក្ដីប្រាថ្នាពេញទីដែលឃើញរូបពណ៌ផៃនាងនេះល្អលើសនាងមុន ប្រើនស្ទួនស្មើនឹងចប់ខ្លួនមិនឈ្នះ តែហ្វូងសត្វមានមានះគិតផ្ដាប់ចិត្តថាខ្លួនយើង កើតមកជាមនុស្សមិនត្រូវទ្រុស្តអកមានគុណ យើងក៏បានគិតពីមុនស្រេចហើយ ត្រូវធ្វើឲ្យជួបគិតឲ្យបាន ។

ហ្វូងសត្វ ក្រោកវៀលវៀកប្រាណមិនឲ្យកម្រើកខ្ទាប



នាងលើកជើងទំប្រឹងទាត់ចេញពីមុខមកនាងតែប្រាថ្នានឹងបើកទ្វារកេ តែក្រង់គេជិននឹងមិនបានស្រួល ក៏មើលទៅឃើញសៀវភៅនៅលើតុ ហ្វូងសត្វក៏តាំងតែអង្គុយសំកុកមើលសៀវភៅឃើញចំរឿងអនុរុទ្ធ កាលទេព្ដាសណ្ដំពារ អនុរុទ្ធយកទៅរួមបន្ទំនឹងនាងឧសា ហ្វូងសត្វមួលបន្ដៀនក្បឿន ឃើញរឿងត្រូវនឹងខ្លួន ក៏អស់សំណើចសើចផឹកៗ ។

នាងកិនយ៉ាន់ឮក៏លើកក្បាលឡើង ថែមក្បែរក៏តាំងទៅមុខផង នាងនេះទើបនឹងគេងលក់ប្រហែល ១ ម៉ោង លុះឃើញហ្វូងសត្វ ក្រោកទៅអង្គុយមើលសៀវភៅ ក៏ឆ្ងល់ណាស់ ចំព្រេះរិះគិតមិនបាត់ឆ្ងល់ សោះលុះពិនិត្យគិតដល់ក្ដើរគោះក្នុងខ្លួន ក៏គ្មានមន្ទិលត្រង់ណា ដឹងច្បាស់ថាហ្វូងសត្វគ្មានត្រូវការនឹងខ្លួនទេ នាងក៏ក្រោកពីគ្រែទៅអង្គុយកៅអីពីម្ខាងហើយជាកបម្លួរហ្វូងសត្វ នាងថា អ្នក

បងម្ដេចក៏មិនសង្គ្រោះខ្ញុំ ? ”

ហ្វូងថា “ បងញាប់តែភ្ញាក់ពីយប់ដូច្នេះបងឆ្ងល់ណាស់ ព្រោះទទួលបានស្រោស្រីដែលមិនដឹងខ្លួន ហើយម្ដេចបានជាមកដេកដំណេកអូនទៅវិញ អ្នកឯណាគេនាំមក ? ” ។

នាង ថា “ បើអ្នកបងគ្មានដឹងសោះទេឬ ? អ្នកម្ដាយខ្ញុំលើកមក ” ។

ហ្វូង ថា “ បងគ្មានដឹងសោះទេណាអូន ចុះម្ដេចបានជាអ្នកម្ដាយឲ្យលើកបងមកឯណេះវិញ បងញាប់នៅសំណាក់ឯផ្ទះម្ដាយធំខាងណោះ ម្ដេចក៏មិននាំទៅទំលាក់ខាងណោះ ” ។

នាង ថា “ បើអ្នកបងមិនជ្រាបថាខ្ញុំជាប្រពន្ធទេឬ ហើយបានរៀបការពីព្រឹកមិញ ម្ដេចក៏អ្នកបងមានប្រ-សាសន៍ដូច្នេះ ”

ហ្វូង គក់ដើមទ្រូងហើយថា “ ចុះរៀបពីអង្កាល់



ហើយរៀប ម្ដេចក៏មិនឲ្យបងជាស្វាមីខ្លួនដឹងផងដូច្នេះ ព្រះម្ចាស់ថ្លៃ ?

នាង ថា “ ឱព្រះអើយ ខ្ញុំស្មានថាម្ដាយធំទីងលោកមាខ្ញុំជួបជុំដំនុំគ្នា ដឹងពាក្យសំដីដល់ខ្លួនអ្នកបងវែរ ខ្ញុំញាប់ទម្លាប់ស្រុកភ្នំពេញ ខាងខ្មែរគេរៀបការតែយ៉ាងគេដូចគ្នាតាំងពីរ យ៉ាងទៀតគេឲ្យតែខាងស្រីក្រាបសំពះម្នាក់ឯងនោះ ព្រោះប្ដីជាមន្ត្រីធំខ្ពស់មានយសសក្តិ គេដាក់តែវត្ថុ ១ មកគំរប់ការក៏បាន ខ្ញុំនឹកស្មានយ៉ាងហ្នឹងបានជាទទួលប្រសាសន៍តាស់ទុំ ព្រមមករួមដំណេកជាមួយបង ខ្ញុំពុំដឹងជាអ្នកបងមិនមែនប្ដីខ្ញុំយ៉ាងនេះសោះ បើដូច្នោះខ្លួនខ្ញុំវេលានេះពេញជាមនុស្សអប្បលក្ខណ៍ណាស់ ខ្ញុំនឹងរស់នៅជាមនុស្សក៏ធ្ងន់ដី ក្នុងវេលារាត្រីនេះខ្ញុំ នឹងសុំលាបងស្លាប់មុនគេ កុំឲ្យឃើញមុខខ្ញុំតាន់ ខ្ញុំមិនមែនប្រកាន់ពីព្រោះអ្នកបងមិនគប់ភាន់ប៉ុណ្ណោះទេ ខ្ញុំខ្មាសគេតែពីព្រោះ

អ្នកបងប្រកែកថា មិនមែនប្ដីប្រពន្ធនឹងគ្នា នាំ
ក៏យំក្រាបលើគុ ហើយថាម៉ែនឹងខាងខ្ញុំ មិនឲ្យ
គេដល់ទីនេះសោះ ខ្ញុំខ្មាសគេណាស់ព្រះអើយ

ហ៊ួន ក្រោកទៅអង្អែលខ្នងនាងហើយ
កាលនឹងកួចចិត្តគិតសម្ងាត់ខ្លួនដូចម្ដេចមិនត្រូវទេ
និយាយសិន អូន ៗ ដែរកាលពេលបា
លើកកែវស្រាឡើង ហើយនិយាយថា
ទៅជាប់សប្បុរសដូចរស់ថ្ងៃនេះកុំសាបរេ
នេះហើយដែលបងប្ដេជ្ញាជាសច្ចំពោះ
នឹងប្រាប់ថា អូនគង់ជាប្រពន្ធបង
តែថ្ងៃនេះនៅមិនទាន់ជាប្រពន្ធច្បាស់
មាតាបងព្រមជាមុនសិនទើបបាន
ពាក្យនេះត្រឡប់ជាខុសទៅវិញ

នាង ថា "មាតាអ្នក ដែ



ថានោះនឹងយកសំអាងត្រង់ណាជាការគួរជឿបាន ?

ហ៊ួន ថា "បងត្រូវសួរអូនឯងវិញ ពាក្យបងថា គង់នឹងយកអូនផង ធ្វើជាប្រពន្ធជាប្រាកដទៅថ្ងៃមុខនោះ អូនឯងជឿបងឬទេ ?"

នាង ថា "ចាស ខ្ញុំជឿតែត្រង់ខ្លួនអ្នកបង ឯត្រង់មាតាខ្ញុំមិនទាន់ជឿ"

ហ៊ួន ថា "បើអូនជឿបងថាហើយ បងនឹងហើយជាសំអាងគួរឲ្យនាងជឿហេតុដល់មាតាផង អូនឯងដែលឃើញគេលើកសសរផ្ទះឬទេ គេលើកសសរណាមុន ?

នាង ថា 'ចាស ខ្ញុំធ្លាប់ឃើញដែរ គេច្រើនលើកសសរកណ្ដាល ត្រង់ល្វែងចាំមុខគេបង្អស់ ទើបគេលើកសសរឯទៀតហេតុដល់សសរជើងរៀង"

ហ៊ួន ថា ម៉េចក៏ចាំតែកណ្ដាលល្វែងតាំង បើលើកជើងរៀងមុនសង់ផ្ទះមិនកើតឬអី ?"

នាង ថា តាស សង់ថ្មីមិនកើត តែបុរសគេសន្មត ទុកមកជាសសរកោងគ្មានល្អិតទាំង ជាមេលំផ្ទះជាសេរីសួស្តីមង្គល,,

ហ្វូនថា មាតាបងមេលំលើបុត្រធីតា ហើយបានជាបងប្រកាន់ឲ្យមាតាសម្រេច ម៉េចក៏នៅតែប្រកែកមិនជឿទៀត..

នាងបានដឹងសេចក្ដីទាំង ក៏អស់សង្ស័យទើបថា បើបងឃ្លាតចាកទៅហើយ ខ្ញុំមានសេចក្ដីរលឹកអាល័យណាស់ ខ្ញុំសុំអ្វីមួយទុកជាតំណាងសេចក្ដីរលឹក និងតំណាងសេចក្ដីជឿផង ។

ហ្វូន ថា «អូនឯងកើតឆ្នាំអី អាយុប៉ុន្មានហើយ»

នាង ថា «តាស ខ្ញុំកើតឆ្នាំកុរ អាយុ ១៨ ឆ្នាំ

ហ្វូនដោះក៏ចិញ្ចៀន១ វង់ត្បូងកណ្ដៀងតាំងគ្រាប់ បំពាក់ឲ្យត្រូវល្មមនឹងដៃនាង ហើយថាឆ្នាំកុរគេ ត្រូវឲ្យពាក់



ចិញ្ចៀនត្បូងកណ្ដៀងជាសិរីសួស្ដីតាមក្បួនគេ អូនត្រូវសំគាល់មើលចិញ្ចៀននេះ បើចិញ្ចៀននេះរលាយបាត់ ទើបចិត្តបងប្រែប្រួលខូចបងស្លាប់ ចុះអូនបានអ្វីបញ្ចាំចិត្តឲ្យបងវិញតំណាងរលឹកផង ។

នាង ក៏ដោះខ្សែស្រង្វាគោមួយខ្សែរហើយបំពាក់ឲ្យប្ដីបញ្ចាំ អ្នកទាំងពីរនាក់នេះមិនទាន់ជាប្ដីប្រពន្ធពេញទីទេ តែបូរាណហៅថា ប្ដីបញ្ចាំប្រពន្ធបញ្ចាំ មានក្នុងច្បាប់ក្រមខុសភរិយា ប្រុសណាទៅលួចសហាយ ត្រូវទោសស្មើប្រពន្ធពេញទី ។

លុះព្រឹកឡើងនាងកិនយ៉ាន់ ក៏ប្រញាប់ពីគេងទៅជួបម្ដាយ ឯផ្ទះបាយម្ដាយលួចក្រឡេកមើលមុខចាត់ឃើញនៅដដែល ក៏ខ្សឹបសួរ ។

ម្ដាយ ថា មេនាងយប់មិញឯងឡូកអីខ្លះ ?

កូន ថា មានឡូកអី នៅធម្មតា»